-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១.**-បំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៨រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ នៅខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយប្រាក់ស្ថាបនាជាតិ**

| | | |
|---|---|---|
| ១-ឯកឧត្តម | **សុខ ខា** | សប្បុរសជនរាជធានីភ្នំពេញថវិកា ២០ ០០០ ០០០ រៀល |
| ២-ឯកឧត្តមឧត្តមសេនីយ៍ឯក | **រ័ត្ន ស្រ៊ាង** | សប្បុរសជនរាជធានីភ្នំពេញថវិកា ២០ ០០០ ០០០ រៀល |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ដួង ហេង** | សប្បុរសជនរាជធានីភ្នំពេញថវិកា ២០ ០០០ ០០០ រៀល |
| ៤-ឯកឧត្តម | **ចាន់ សុធុឡា** | សប្បុរសជនរាជធានីភ្នំពេញថវិកា ២០ ០០០ ០០០ រៀល |
| ៥-ឯកឧត្តមបណ្ឌិត | **ប៉ា ម៉េងហុក** | សប្បុរសជនរាជធានីភ្នំពេញថវិកា ២០ ០០០ ០០០ រៀល |
| ៦-ឯកឧត្តម | **មួន ឆាសនា** | សប្បុរសជនរាជធានីភ្នំពេញថវិកា ២០ ០០០ ០០០ រៀល |
| ៧-ឯកឧត្តម | **ផន សុភ័ក្រ** | សប្បុរសជនរាជធានីភ្នំពេញថវិកា ២០ ០០០ ០០០ រៀល |
| ៨-ឯកឧត្តម | **អ៊ុច សុភាព** | សប្បុរសជនរាជធានីភ្នំពេញថវិកា ២០ ០០០ ០០០ រៀល |

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ**

| | | |
|---|---|---|
| ១-ឯកឧត្តម | **តាំង គក់** | សប្បុរសជនរាជធានីភ្នំពេញថវិកា ១០ ០០០ ០០០ រៀល |
| ២-លោក | **ជិម សុវណ្ណា** | សប្បុរសជនខេត្តសៀមរាប ថវិកា ១០ ០០០ ០០០ រៀល |
| ៣-លោកស្រី | **ចំរើន សុស៊ីវណ្ណា** | សប្បុរសជនខេត្តសៀមរាប ថវិកា ១០ ០០០ ០០០ រៀល |
| ៤-លោក | **ច្រាំ សុមាលី** | សប្បុរសជនរាជធានីភ្នំពេញថវិកា ១០ ០០០ ០០០ រៀល |
| ៥-លោក | **ម៉ក់ ម៉ូនី** | សប្បុរសជនរាជធានីភ្នំពេញថវិកា ១០ ០០០ ០០០ រៀល |

| | | |
|---|---|---|
| ៦-លោក | **ហុក ធិឲ្យរុទ្ធា** | សប្បុរសជនរាជធានីភ្នំពេញថវិកា ១០ ០០០ ០០០ រៀល |
| ៧-លោក | **តែម វ៉ា** | សប្បុរសជនរាជធានីភ្នំពេញថវិកា ១០ ០០០ ០០០ រៀល |
| ៨-លោក | **សាពាយ តី** | សប្បុរសជនរាជធានីភ្នំពេញថវិកា ១០ ០០០ ០០០ រៀល |
| ៩-លោក | **ដួង អៀង** | សប្បុរសជនរាជធានីភ្នំពេញថវិកា ១០ ០០០ ០០០ រៀល |
| ១០-កញ្ញា | **ដួង ម៉ី** | សប្បុរសជនរាជធានីភ្នំពេញថវិកា ១០ ០០០ ០០០ រៀល |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំនិង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ៤ កើត ខែ ទុតិយាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៥៨រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ នៅខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | |
|---|---|---|
| ១-លោក | **នួន នី** | មន្ត្រីរាជការ |
| ២-លោក | **ហ៊ិន ឈាង** | មន្ត្រីរាជការ |
| ៣-លោក | **ហ៊ិន ឈន់** | មន្ត្រីរាជការ |
| ៤-ឧបាសិកា | **ខន គឹមហាន** | មន្ត្រីរាជការ |
| ៥-លោកគ្រូ | **ជា ឌី** | មន្ត្រីរាជការ |
| ៦-លោក | **តឿន ត័ណ្ឌ** | មន្ត្រីរាជការ |
| ៧-វរសេនីយ៍ត្រី | **ឈួង សំប៊ុន** | មន្ត្រីរាជការ |
| ៨-លោកស្រីវេជ្ជបណ្ឌិត | **រាជ សីលា** | មន្ត្រីរាជការ |
| ៩-លោកស្រីវេជ្ជបណ្ឌិត | **រាជ សុខា** | មន្ត្រីរាជការ |
| ១០-លោក | **កែវ សុវណ្ណារិទ្ធ** | មន្ត្រីរាជការ |

**ខ-មេដាយប្រាក់ការងារ**

| | | |
|---|---|---|
| ១-លោក | **ឈឹម ឌិន** | មន្ត្រីរាជការ |
| ២-លោក | **ទេព តារាម្សៃ** | មន្ត្រីរាជការ |
| ៣-លោក | **ជៀប ឆេង** | មន្ត្រីរាជការ |
| ៤-លោក | **ឆាន ឈី** | មន្ត្រីរាជការ |

| | | |
|---|---|---|
| ៥-លោក | **ឃឹម ឡូន** | មន្ត្រីរាជការ |
| ៦-លោក | **ព្រុំ ភន** | មន្ត្រីរាជការ |
| ៧-លោក | **ញាណា ដាន** | មន្ត្រីរាជការ |
| ៨-លោក | **ម៉ា ហុយ** | មន្ត្រីរាជការ |
| ៩-លោកស្រី | **រ៉ាត់ តាង** | មន្ត្រីរាជការ |
| ១០-លោក | **ជុំ សាមិន** | មន្ត្រីរាជការ |
| ១១-លោកស្រីវេជ្ជបណ្ឌិត | **សុខ ស្រីណា** | មន្ត្រីរាជការ |
| ១២-លោកវេជ្ជបណ្ឌិត | **តោត ម៉ិន** | មន្ត្រីរាជការ |
| ១៣-លោកវេជ្ជបណ្ឌិត | **ឆាត សុខសម្ភជា** | មន្ត្រីរាជការ |
| ១៤-លោកវេជ្ជបណ្ឌិត | **សាំង សុខសាន** | មន្ត្រីរាជការ |
| ១៥-លោកវេជ្ជបណ្ឌិត | **សំ សាឡឿន** | មន្ត្រីរាជការ |
| ១៦-លោកវេជ្ជបណ្ឌិត | **ម៉ារ៉ាយ៉ា មុនីសា** | មន្ត្រីរាជការ |
| ១៧-លោកស្រីវេជ្ជបណ្ឌិត | **ម៉ែន មាលា** | មន្ត្រីរាជការ |
| ១៨-លោកវេជ្ជបណ្ឌិត | **ឆេង ពិសី** | មន្ត្រីរាជការ |
| ១៩-លោកវេជ្ជបណ្ឌិត | **ទូច សុខឡេង** | មន្ត្រីរាជការ |
| ២០-លោកស្រីឱសថការី | **ផាន់ ទាចារ** | មន្ត្រីរាជការ |
| ២១-លោកស្រីឱសថការី | **ឱុយ ថៃត** | មន្ត្រីរាជការ |
| ២២-លោកស្រីឱសថការី | **យស បញ្ញា** | មន្ត្រីរាជការ |
| ២៣-លោកស្រីឱសថការី | **ចាប ចាន់ធា** | មន្ត្រីរាជការ |
| ២៤-លោកស្រីឱសថការី | **ឃុន សុភក្តិ** | មន្ត្រីរាជការ |
| ២៥-លោកស្រីឱសថការី | **ខុត គីមឡាំង** | មន្ត្រីរាជការ |
| ២៦-លោកស្រីគិលានុបដ្ឋាក | **ឈុន ថាលីន** | មន្ត្រីរាជការ |
| ២៧-លោកស្រីគិលានុបដ្ឋាក | **ទូច ចាន់ណារ៉ា** | មន្ត្រីរាជការ |
| ២៨-លោកស្រីគិលានុបដ្ឋាក | **រស់ សោភី** | មន្ត្រីរាជការ |
| ២៩-លោកគិលានុបដ្ឋាក | **គា លីហេង** | មន្ត្រីរាជការ |
| ៣០-លោកគិលានុបដ្ឋាក | **សែម រដ្ឋា** | មន្ត្រីរាជការ |
| ៣១-លោកស្រីគិលានុបដ្ឋាក | **ស៊ុន យ៉ាណាក់** | មន្ត្រីរាជការ |
| ៣២-លោកគិលានុបដ្ឋាក | **ហែម ចំរើន** | មន្ត្រីរាជការ |
| ៣៣-លោកគិលានុបដ្ឋាក | **លី សារឿន** | មន្ត្រីរាជការ |
| ៣៤-លោកគិលានុបដ្ឋាក | **ហ៊ាង ថៃត** | មន្ត្រីរាជការ |
| ៣៥-លោកស្រី | **ហុត ធិច្ចកេសា** | មន្ត្រីរាជការ |

**គ-មេដាយសំរឹទ្ធការងារ**

| | | |
|---|---|---|
| ១-លោក | **ពៀន ឡុន** | មន្ត្រីរាជការ |
| ២-លោក | **ភុល អឿង** | មន្ត្រីរាជការ |
| ៣-លោក | **ប៊ុត ម៉ៃ** | មន្ត្រីរាជការ |
| ៤-លោក | **ហ៊ឹម រិន** | មន្ត្រីរាជការ |
| ៥-លោក | **ជា នឿន** | មន្ត្រីរាជការ |
| ៦-លោក | **ហ៊ី សេង** | មន្ត្រីរាជការ |

| | | |
|---|---|---|
| ៧-លោក | **មិន ជឿន** | មន្ត្រីរាជការ |
| ៨-លោក | **សន សារិន** | មន្ត្រីរាជការ |
| ៩-លោក | **ហ៊ូ ពៅ** | មន្ត្រីរាជការ |
| ១០-លោក | **ពេជ ហ៊ីន** | មន្ត្រីរាជការ |
| ១១-លោក | **ថ្លាំ ឿ្យន** | មន្ត្រីរាជការ |
| ១២-លោកស្រី | **ម៉ុខ ផល្លា** | មន្ត្រីរាជការ |
| ១៣-លោកស្រី | **ហុក ធិព្វតីមឡាយ** | មន្ត្រីរាជការ |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំនិង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ថ្ងៃចន្ទ ៤ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧៤៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១..** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេននិងជូនសប្បុរសជន ចំនួន៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-ព្រះតេជគុណ **ស៊ុន ហុក** | | ព្រះចៅអធិការវត្តពោធិមានលក្ខណ៍ |
| ២-លោក | XU CHAO YUN | សប្បុរសជន |
| ៣-លោក | WEN ZHI YONG | សប្បុរសជន |

**មាត្រា២..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៥កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៨
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ...៧៤៤...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១.**. បំពាក់ **មេដាយមាសការងារ** ជូនពលទាហាន ចំនួន ២ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-ពលទោ **កែវ ចាន់បូនីតា** អត្តលេខ ២៣៤៣៨៦
២-ពលទោ **ទេព ចាន់ដា** អត្តលេខ ០៩៤៥២៨

**មាត្រា២.**. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ថ្ងៃ សុក្រ ៥ កើត ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៨
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៤៧ សសរ**

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៨/ ២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២.លោកជំទាវ | **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣.ឯកឧត្តម | **ជូ ទិដិត្ថ** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤.ឯកឧត្តម | **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៥.ឯកឧត្តម | **ឃីម ប៊ុនសុង** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធាន |
| ៦.ឯកឧត្តម | **ស៊ូ តិរិទ្ធ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧.ឯកឧត្តម | **ទី ច័ន្ទ្រផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨.ឯកឧត្តម | **ជា ម៉ូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៩.ឯកឧត្តម | **និត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១០.ឯកឧត្តម | **ថៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១.ឯកឧត្តម | **ស៊ឹម យ៉ារ៉ែន** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១២.ឯកឧត្តម | **ឈន សុភាព** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣.ឯកឧត្តម | **សុខ គុងហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៤.ឯកឧត្តម | **អ៊ុន ឆឹម** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៥.ឯកឧត្តម | **លី សំរឹទ្ធិ** | អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ១៦.ឯកឧត្តម | **សុខ សង្វារ** | អគ្គនាយករងអាជ្ញាធរជាតិអប្សរា | សមាជិក |

**ប្រការ២._**

គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប មានតួនាទី និងភារកិច្ចដូចតទៅ÷

-រៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងខេត្តសៀមរាបដោយផ្អែកលើប្លង់មេនៃការប្រើប្រាស់ដីធ្លីរបស់ខេត្តសៀមរាប ដើម្បីធានាបាននូវការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយចីរភាព មានរបៀបរៀបរយ មានសណ្ដាប់ធ្នាប់ល្អ ទាំងការអភិរក្ស និងការអភិវឌ្ឍទីក្រុងសៀមរាប

-សិក្សា រៀបចំបង្កើតឱ្យមានផលិតផលទេសចរណ៍ថ្មីៗនៅក្នុងខេត្តសៀមរាប សំដៅបង្កើនការទាក់ទាញភ្ញៀវទេសចរបន្ថែម និងពន្យារការស្នាក់នៅរបស់ភ្ញៀវ

-ពិនិត្យ សិក្សា រៀបចំឱ្យមានជាព្រឹត្តិការណ៍វប្បធម៌ សិល្បៈកំសាន្តធំៗនៅពេលយប់ ទាំងបុរាណ និងទំនើប ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ដែលអាចសហការរៀបចំជាមួយវិស័យឯកជន នៅតាមទីតាំងប្រាសាទមួយចំនួន ដោយយើងអាចគ្រប់គ្រងរក្សាការពារ អភិរក្សបាន និងមិនធ្វើឱ្យប៉ះពាល់ដល់ទីតាំងប្រាសាទ

-ពិនិត្យ សិក្សា រៀបចំរមណីយដ្ឋានទេសចរណ៍ធម្មជាតិ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ ដែលមានមានសក្ដានុពលផ្សេងទៀតនៅក្នុងខេត្តសៀមរាប

-ធ្វើរបាយការណ៍អំពីលទ្ធផល ឬរាយការណ៍អំពីវឌ្ឍនភាពការងាររបស់ខ្លួនជូនរាជរដ្ឋាភិបាលជ្រាប និងសុំការណែនាំ យ៉ាងយូរបីខែម្ដង

-បំពេញភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣._**

សមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មការ អាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការងារ និងកិច្ចប្រជុំជំនួស។

**ប្រការ៤._**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសតាមការចាំបាច់ ដែលមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ប្រការ៥._**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៦._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ១៣ រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែសីហា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ៧

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៤៧ ...សហវ.ប្រក

ប្រកាស
ស្តីពី
ការតែងតាំងជំនួយការចំណូល
នៅក្រុមប្រឹក្សាជាតិគណនេយ្យ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ. ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៨៤២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការ នៅក្រុមប្រឹក្សាជាតិគណនេយ្យ ដូចខាងក្រោម÷

១. លោក **លី កុសល** មន្ត្រីការិយាល័យបញ្ញត្តិកម្មនិងត្រួតពិនិត្យនៃ ក.ជ.គ. ជារជ្ជទេយ្យករចំណូល

២. លោក **យេម នៃយ៉ា** មន្ត្រីការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុនៃ ក.ជ.គ. ជារជ្ជទេយ្យករចំណូលរង។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ[illegible] ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៧០ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងថ្នាក់ដឹកនាំប្រឹក្សាការបុរេប្រទាន
## របស់អគ្គនាយកដ្ឋានប្រេងកាត
## នៃក្រសួងរ៉ែនិងថាមពល

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែនិងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧នៃអនុក្រឹត្យ លេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសអន្តរក្រសួងលេខ ៤៦២ រថ.អកទទ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ០៨៧ រថ.គហ.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិការដ្ឋបាលកណ្តាល នៃក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្រហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល

**សម្រេច**

**ប្រការ ១**. -

ត្រូវបានតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង របស់អគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- លោក ខ្លឹម ច័ន្ទរាត្រី | ឲ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទាន |
| ២- លោក ព្រូ ប៊ុនឡាយ | ឲ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទានរង |
| ៣- លោក សេង រមនី | ឲ្យទទួលបន្ទុកការងារជារដ្ឋទេយ្យករបុរេប្រទានរង |

**ប្រការ ២**. -

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ព្រមទាំងសាមីខ្លួនដូចប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឆ្នាំ ២០១៨

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៦៣ ...... សហវ.ប្រក

# ប្រកាស

# ស្ដីពី

# យន្តការបង្វិលសងអាករលើតម្លៃបន្ថែម

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីអាករលើតម្លៃបន្ថែម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងរៀបចំយន្តការបង្វិលសងអាករលើតម្លៃបន្ថែមឱ្យមានប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព ដើម្បីធានាបាននូវការជឿទុកចិត្តពីអ្នកជាប់ពន្ធក្នុងការបង្វិលសងប្រាក់អាករលើតម្លៃបន្ថែម។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់នូវលក្ខខណ្ឌនិងលក្ខណសម្បត្តិនៃការស្នើសុំបង្វិលសង និងវិហ្វរការងារ បង្វិលសងអាករលើតម្លៃបន្ថែមដើម្បីឱ្យការស្នើសុំបង្វិលសងបានឆាប់រហ័សស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការស្នើសុំបង្វិលសងរបស់សហគ្រាសទាំងឡាយ ដែលបាន ចុះបញ្ជីពន្ធដារ ហើយមានផលរបរចាប់ពីកម្រិតអ្នកជាប់ពន្ធមធ្យមឡើងទៅ និងបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

**ប្រការ ៤.- លក្ខខណ្ឌនៃការស្នើសុំបង្វិលសង**

១. យោងតាមមាត្រា៧២ និងមាត្រា៧៣ នៃច្បាប់ស្តីពីសារពើពន្ធ មាត្រា៤០ និងមាត្រា៤១ នៃអនុក្រឹត្យស្តីពី អាករលើតម្លៃបន្ថែម អ្នកជាប់ពន្ធដែលមានសិទ្ធិស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែមត្រូវមានលក្ខខណ្ឌ ដូចខាងក្រោម÷

ក. មានឥណទានអាករលើធាតុចូលលើសប្រចាំខែ ចំពោះបុគ្គលជាប់អាករដែលមានការនាំចេញជាសំខាន់ ឬបានចុះបញ្ជីជាសហគ្រាសវិនិយោគ

ខ. មានឥណទានអាករលើធាតុចូលលើសចាប់ពី ៣ ខែ ជាប់គ្នា ឡើងទៅ ចំពោះបុគ្គលជាប់អាករដទៃទៀត

គ. មានភស្តុតាងនៃការបង់ប្រាក់អាករលើធាតុចូល រួមមានប្រតិវេទន៍គយសម្រាប់ការនាំចូលព្រមទាំង ច្បាប់ដើមនៃបង្កាន់ដៃគយដែលបញ្ជាក់ពីការបង់ប្រាក់អាករដែលអាចអនុញ្ញាតជាឥណទាន ឬច្បាប់ដើមនៃ វិក្កយបត្រអាករចេញដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក

ឃ. មានភស្តុតាងនៃការនាំចេញដែលត្រូវជាប់អាករតាមអត្រាសូន្យ

ង. មានបញ្ជីគណនេយ្យអាករលើតម្លៃបន្ថែមដែលអាចជឿទុកចិត្តបាន រួមមាន ទិនានុប្បវត្តិទិញ-លក់ ព្រមទាំងកំណត់ត្រាជំនួយផ្សេងៗ។

២. ចំពោះបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា ការស្នើសុំបង្វិលសងត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម÷

ក. ចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន

ខ. ដាក់ពាក្យស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារតាមទម្រង់ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ

គ. វិក្កយបត្រទិញនីមួយៗត្រូវមានទឹកប្រាក់សរុបមិនទាន់គិតអាករ ចាប់ពី ២០០ ០០០ រៀលឡើងទៅ

ឃ. ពាក្យស្នើសុំបង្វិលសងនីមួយៗត្រូវមានទឹកប្រាក់សរុបមិនទាន់គិតអាករចាប់ពី ២ ០០០ ០០០ រៀល ឡើងទៅ

ង. ពាក្យស្នើសុំត្រូវមានការបញ្ជាក់ពីប្រធានបេសកកម្ម ជូនអគ្គនាយកដ្ឋានពន្ធដារថា ទំនិញត្រូវបាន ទិញសម្រាប់យកមកប្រើប្រាស់ក្នុងការបំពេញមុខងារជាផ្លូវការរបស់បេសកកម្មពិតប្រាកដមែន។

**ប្រការ ៥.- នីតិវិធីការទារបង្វិលសងអាករលើតម្លៃបន្ថែម**

១. សម្រាប់ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ចំពោះក្រុមហ៊ុន ត្រូវអនុវត្តដូចខាងក្រោម÷

- អ្នកជាប់ពន្ធត្រូវបំពេញនិងដាក់លិខិតប្រកាសនិងស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម តាមទម្រង់បែបបទដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ
- នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវកត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ (Document Tracking System) ដោយមានបារកូដសម្រាប់តាមដាន បន្ទាប់មកបញ្ជូនត្រឡប់ទៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ
- បន្ទាប់ពីបានកត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធត្រូវរៀបចំឯកសារដើម្បីធ្វើសវនកម្មផ្ទៀងផ្ទាត់ និងបញ្ជូនលទ្ធផលជូនថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេច
- ក្នុងករណីអ្នកជាប់ពន្ធទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស អគ្គនាយកដ្ឋានពន្ធដារអាចពិនិត្យសម្រេចអនុញ្ញាតផ្តល់ជូនតែម្តងដោយពុំចាំបាច់ធ្វើសវនកម្មផ្ទៀងផ្ទាត់ជាមុន ឬធ្វើសវនកម្មតាមក្រោយក្នុងករណីចាំបាច់
- ក្រោយពីទទួលបានការសម្រេចរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំអាណត្តិបើកប្រាក់ ចុះលេខលើអាណត្តិបើកប្រាក់ និងកត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រ កត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុលើសំណុំឯកសារអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅរតនាគារជាតិ
- បន្ទាប់មក នៅពេលទឹកប្រាក់បង្វិលសងត្រូវបានផ្ទេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារត្រូវបញ្ជូនលិខិតជូនដំណឹងស្តីពីការផ្តល់ជូនប្រាក់ស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ភ្ជាប់នឹងមូលប្បទានបត្រ ជូនអ្នកជាប់ពន្ធ។

២. សម្រាប់ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ចំពោះបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានាត្រូវអនុវត្តដូចខាងក្រោម÷

- បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានាត្រូវដាក់លិខិតស្នើសុំដោយផ្ទាល់មកនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ
- នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវកត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ (Document Tracking System) ដោយមានបារកូដសម្រាប់តាមដាន បន្ទាប់មកបញ្ជូនទៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ
- បន្ទាប់ពីបានកត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធត្រូវពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារស្នើសុំបង្វិលសង និងបញ្ជូនលទ្ធផលជូនថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេច
- ក្រោយពីទទួលបានការសម្រេចរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំអាណត្តិបើកប្រាក់ ចុះលេខលើអាណត្តិបើកប្រាក់ និង

កត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រ កត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុលើសំណុំឯកសារអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅរតនាគារជាតិ

- នៅពេលទឹកប្រាក់បង្វិលសងត្រូវបានផ្ទេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវបញ្ជូនលិខិតជូនដំណឹងស្តីពីការផ្តល់ជូនប្រាក់ស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ភ្ជាប់នឹងមូលប្បទានបត្រ ជូនអ្នកជាប់ពន្ធ។

តារាងវិហ្វូរការងារបង្វិលសងអាករលើតម្លៃបន្ថែម មានភ្ជាប់ជាឧបសម្ព័ន្ធ ជាមួយនឹងប្រកាសនេះ។

**ប្រការ ៦.- ភារកិច្ចរបស់អ្នកស្នើសុំបង្វិលសង**

ដើម្បីធានាឱ្យការបង្វិលសងប្រព្រឹត្តទៅបានឆាប់រហ័ស អ្នកជាប់ពន្ធ ឬបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានាត្រូវផ្តល់បញ្ជីគណនេយ្យនិងឯកសារនានា ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ ឱ្យបានគ្រប់គ្រាន់និងតាមពេលវេលាកំណត់របស់អគ្គនាយកដ្ឋានពន្ធដារ ពុំនោះទេការស្នើសុំបង្វិលសងនឹងត្រូវបានព្យួរទុករហូតដល់ថ្ងៃដែលអគ្គនាយកដ្ឋានពន្ធដារបានទទួលបញ្ជីគណនេយ្យនិងឯកសារគ្រប់គ្រាន់។

**ប្រការ ៧.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសនិងស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...................សហវ

## ឧបសម្ព័ន្ធទី១

## រំហូរនៃការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែមសម្រាប់ក្រុមហ៊ុន

ភ្ជាប់ជាមួយប្រកាសលេខ.៥៧១... សហវ.ប្រក ចុះថ្ងៃទី១៩.ខែ.ធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**អ្នកជាប់ពន្ធដាក់លិខិតប្រកាសនិងស្នើសុំ**

↓

| ល.រ | អង្គភាព | សកម្មភាព |
|---|---|---|
| ១ | **នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអពដ** | កត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ (Document Tracking System) ដោយមានបិទបារកូដសម្រាប់តាមដាន បន្ទាប់មកបញ្ជូនត្រឡប់ទៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ |
| ២ | **អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ នៃអពដ** | ទទួលលិខិតប្រកាសរបស់អ្នកជាប់ពន្ធដែលស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម តាមទម្រង់បែបបទដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងត្រូវរៀបចំឯកសារដើម្បីធ្វើសវនកម្មផ្ទៀងផ្ទាត់ និងបញ្ជូនលទ្ធផលជូនថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេច ឬក្នុងករណីអ្នកជាប់ពន្ធទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស អគ្គនាយកដ្ឋានពន្ធដារអាច ពិនិត្យសម្រេចអនុញ្ញាតផ្តល់ជូនតែម្តងដោយពុំចាំបាច់ធ្វើសវនកម្មផ្ទៀងផ្ទាត់ជាមុន ឬធ្វើសវនកម្មជាក្រោយក្នុងករណីចាំបាច់ |
| ៣ | **ថ្នាក់ដឹកនាំ នៃអពដ ពិនិត្យសម្រេច** | ថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានពន្ធដារ ពិនិត្យសម្រេច លើសំណុំឯកសារស្នើសុំ |
| ៤ | **នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអពដ** | - រៀបចំអាណត្តិបើកប្រាក់ ចុះលេខលើអាណត្តិបើកប្រាក់ និងកត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រ កត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុលើសំណុំឯកសារអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅរតនាគារជាតិ<br>- បញ្ជូនលិខិតជូនដំណឹងភ្ជាប់នឹងមូលប្បទានបត្រ ជូនអ្នកជាប់ពន្ធ នៅពេលទឹកប្រាក់បង្វិលសងត្រូវបានផ្ទេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា |
| ៥ | **អគ្គនាយកដ្ឋានរតនាគារជាតិ** | បង្វែរប្រាក់បង្វិលសងអាករលើតម្លៃបន្ថែមចូលទៅគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា |

**កំណត់សម្គាល់÷**

ការបង្វិលសងអាករលើតម្លៃបន្ថែមចំពោះក្រុមហ៊ុននានានឹងប្រើប្រាស់រយៈពេលប្រហែល ៤០ ថ្ងៃ នៃថ្ងៃធ្វើការ ឬឆាប់ជាងនេះសម្រាប់សហគ្រាសដែលទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...................សហវ

## ឧបសម្ព័ន្ធទី២

## ស្តីពី

## នីតិវិធីនៃការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែមសម្រាប់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានា

ភ្ជាប់ជាមួយប្រកាសលេខ............. សហវ.ប្រក ចុះថ្ងៃទី...... ខែ.......... ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**បេសកកម្មទូត អង្គការអន្តរជាតិ...ដាក់លិខិតស្នើសុំ**

| | | |
|---|---|---|
| ១ | **នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃអពដ** | កត់ត្រាវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងនិងតាមដានឯកសារ (Document Tracking System) ដោយមានបិទបារកូដសម្រាប់តាមដាន បន្ទាប់មកបញ្ជូនទៅអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ |
| ២ | **អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ នៃអពដ** | ពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារស្នើសុំបង្វិលសង និងបញ្ជូនលទ្ធផលជូនថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេច |
| ៣ | **ថ្នាក់ដឹកនាំ នៃអពដ ពិនិត្យនិងសម្រេច** | ថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំ |
| ៤ | **នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអពដ** | - រៀបចំអាណត្តិបើកប្រាក់ ចុះលេខលើអាណត្តិបើកប្រាក់ និងកត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រ កត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុលើសំណុំ ឯកសារអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅរតនាគារជាតិ<br>- បញ្ជូនលិខិតជូនដំណឹងភ្ជាប់នឹងមូលប្បទានបត្រ ជូនអ្នកជាប់ពន្ធ នៅពេលទឹកប្រាក់បង្វិលសងត្រូវបានផ្ទេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា |
| ៥ | **អគ្គនាយកដ្ឋានរតនាគារជាតិ** | បង្វែរប្រាក់បង្វិលសងអាករលើតម្លៃបន្ថែមចូលទៅគណនីរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជា |

**កំណត់សម្គាល់÷**
ការបង្វិលសងអាករលើតម្លៃបន្ថែមចំពោះបេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការរបស់រដ្ឋាភិបាលនានា នឹងប្រើប្រាស់រយៈពេលប្រហែល **១៥** ថ្ងៃ នៃថ្ងៃធ្វើការ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៩៧ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិចុះហត្ថលេខា ជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុ លើអាណត្តបើកប្រាក់បង្វិលសងប្រាក់អាករលើតម្លៃបន្ថែម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

- ប្រគល់សិទ្ធិជូនឯកឧត្តម **គង់ ទិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ចុះហត្ថលេខាជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុ ក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើសំណុំឯកសារអាណត្តិបើកប្រាក់ជំពូក ៦៣ គណនី ៧០០៩ អនុគណនី ៧០០៩១ "ការបង្វិលសងវិញនូវពន្ធ និងអាករផ្សេងៗ"ជូនដល់គ្រប់សហគ្រាសដែលមានទឹកប្រាក់ត្រឹម ២ ០០០ លានរៀល ចុះ។ ករណីប្រាក់បង្វិលសងប្រាក់អាករលើតម្លៃបន្ថែមមានទឹកប្រាក់ចាប់ពី ២ ០០០ លានរៀលឡើង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកសម្រេចនិងចុះហត្ថលេខាលើសំណុំឯកសារអាណត្តិបើកប្រាក់ក្នុងនាមជាអាណាប័ក។

- ប្រគល់សិទ្ធិជូនឯកឧត្តម **គង់ ទិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ចុះហត្ថលេខាជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុ ក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើសំណុំឯកសារអាណត្តិបើកប្រាក់ជំពូក ៦៣ គណនី ៧០០៩ អនុគណនី ៧០០៩១ "ការបង្វិលសងវិញនូវពន្ធ និងអាករផ្សេងៗ" ជូនដល់គ្រប់ស្ថានទូត អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកជាប់ពន្ធដែលទទួលបានចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធប្រភេទមាស (អនុលោមភាពខ្ពស់) ដោយមិនកំណត់ចំនួនទឹកប្រាក់។

**ប្រការ ២.-**

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចចុះលេខលើសន្លឹកអាណត្តិបើកប្រាក់ និងកត់ត្រាតាមដានស្ថានភាពឥណទានលើសលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ។

**ប្រការ ៣.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ គ្រប់អគ្គនាយក អគ្គាធិការ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ______ ខែ______ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការបង្កើតវង្វេយ្យចំណូល
## នៅក្រុមប្រឹក្សាជាតិគណនេយ្យ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ. ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្ដីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៨៤២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៦ ស្ដីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យចំណូល នៅក្រុមប្រឹក្សាជាតិគណនេយ្យ ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ អនុលោមតាមប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូល ផលដែលរជ្ជទេយ្យករត្រូវបានអនុញ្ញាតឱ្យប្រមូល ដូចខាងក្រោម៖

- អនុគណនី ៧៣០៦៦(ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក) ចំនួនទឹកប្រាក់ ៥៤.០០០.០០០ រៀល

សរុបទឹកប្រាក់៖ ៥៤.០០០.០០០ រៀល

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកក្នុងបេឡាមានកំណត់ត្រឹមចំនួន ២.០០០.០០០ រៀល(ពីរលានរៀលគត់)។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស. ...

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៨

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...........សហវ...........

**ប្រកាស**

**ស្ដីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ**

**អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគណនេយ្យ**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខដំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទៅជាអគ្គនាយកដ្ឋានដោះស្រាយ ផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុលនិងបង្កើតនាយកដ្ឋានសវនកម្ម បច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បកចុះ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៨៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន **ក.ជ.គ.** ដែលមានមុខងារនិងភារកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ១៨៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ ដូចខាងក្រោម÷

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន **ក.ជ.គ.**
- រៀបចំមុខងារ និងភារកិច្ចរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន **ក.ជ.គ.**
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងក្របខ័ណ្ឌនៃការផ្ដល់សេវាគាំទ្រ និងសម្របសម្រួលសកម្មភាពការងារក្នុងអគ្គលេខាធិការដ្ឋាន **ក.ជ.គ.**
- ធានាគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងកិច្ចការអគ្គលេខាធិការដ្ឋាន **ក.ជ.គ.**។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្ត ចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន **ក.ជ.គ.**។

## ជំពូកទី២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**ប្រការ ៤.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.គ.** បំពេញមុខងារជាសេនាធិការរដ្ឋបាល និងបច្ចេកទេសអចិន្ត្រៃយ៍ឱ្យក្រុមប្រឹក្សាជាតិគណនេយ្យលើបេសកកម្មដូចតទៅ÷

- រៀបចំនិងតាមដានការអនុវត្តច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- រៀបចំនិងតាមដានការអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម
- គ្រប់គ្រងអាជីវកម្មគណនេយ្យនិងអាជីវកម្មសវនកម្ម
- តាមដាននិងវាយតម្លៃនិន្នាការវិវឌ្ឍនៃស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករនិងសវនករ ស្តង់ដាអប់រំសម្រាប់វិជ្ជាជីវៈគណនេយ្យ និងស្តង់ដាពាក់ព័ន្ធផ្សេងទៀត
- ចូលរួមចំណែកក្នុងការងារពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- ស្វែងរកដៃគូសហការក្នុងការអភិវឌ្ឍវិស័យគណនេយ្យ និងសវនកម្ម
- ផ្តល់សេវាគាំទ្រសម្រាប់ប្រក្រតីភាព នៃដំណើរការក្រុមប្រឹក្សាជាតិគណនេយ្យ
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

**ប្រការ ៥.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.គ.** មានមុខងារ និងភារកិច្ចដូចតទៅ÷

- ទទួលបន្ទុកការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់ **ក.ជ.គ.**
- រៀបចំកិច្ចប្រជុំរបស់ **ក.ជ.គ.**
- រៀបចំយុទ្ធសាស្ត្រនិងផែនការនានាដើម្បីអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម
- រៀបចំគម្រោងថវិកានិងគ្រប់គ្រងចំណូលចំណាយរបស់ **ក.ជ.គ.**
- រៀបចំនិងគ្រប់គ្រងកិច្ចការអាជ្ញាបណ្ណជូនគណនេយ្យករនិងសវនករ ដើម្បីដាក់ជូន **ក.ជ.គ.** ពិនិត្យនិងសម្រេច
- ធ្វើជាតំណាងឱ្យ **ក.ជ.គ.** នៅចំពោះមុខតុលាការ
- ធ្វើជាសេនាធិការបច្ចេកទេសរបស់ **ក.ជ.គ.**
- អនុវត្តការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា
- លើកសំណើវិធានការចំពោះរាល់ការបំពានច្បាប់គណនេយ្យនិងសវនកម្ម លិខិតបទដ្ឋានពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្មនិងស្តង់ដាគណនេយ្យនិងសវនកម្មព្រមទាំងរៀបចំសេចក្តីសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មពិន័យអន្តរការណ៍ជូន **ក.ជ.គ.** ពិនិត្យនិងសម្រេច
- ធ្វើជាតំណាង **ក.ជ.គ.** ក្នុងទំនាក់ទំនងជាមួយតតិយជនដូចជាអង្គការជាតិនិងអន្តរជាតិព្រមទាំងវិស័យឯកជនក្នុងគោលដៅពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងស្តង់ដានានា និងក្នុងគោលដៅជំរុញកិច្ចអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម
- ទទួលបណ្តឹងតវ៉ាផ្សេងៗ ហើយសិក្សានិងលើកយោបល់ជូន **ក.ជ.គ.** ដើម្បីសម្រេចលើវិធានការសមស្រប

- ជំរុញឱ្យមានមូលដ្ឋានទិន្នន័យពីបណ្តាសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញសម្រាប់ជាមូលដ្ឋានក្នុងការតាមដានការត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តច្បាប់និងស្តង់ដាពាក់ព័ន្ធ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **គ.ជ.គ.** ដើម្បីដាក់ជូន **គ.ជ.គ.** ពិនិត្យនិងសម្រេច
- រៀបចំខ្លឹមសារនៃការពិគ្រោះយោបល់របស់ **គ.ជ.គ.** ជាមួយស្ថាប័នឬអង្គការជាតិនិងអន្តរជាតិជាដៃគូនានា
- លើកសំណើជូន **គ.ជ.គ.** ដើម្បីពិនិត្យពិភាក្សានិងសម្រេចលើសេចក្តីព្រាងច្បាប់ អនុក្រឹត្យ ស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ព្រមទាំងធ្វើបច្ចុប្បន្នកម្មនៃស្តង់ដាទាំងនោះ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ **គ.ជ.គ.**
- អនុវត្តការងារផ្សេងទៀតដែលប្រធាន **គ.ជ.គ.** ប្រគល់ជូន។

**ប្រការ ៦.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.គ.** មានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

១. នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

២. នាយកដ្ឋានអនុលោមភាព និងត្រួតពិនិត្យ

៣. នាយកដ្ឋានកិច្ចការច្បាប់

៤. នាយកដ្ឋានបច្ចេកទេស។

**ប្រការ ៧.-**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុបំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា និងផែនការថវិកា។

នាយកដ្ឋានអនុលោមភាព និងត្រួតពិនិត្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារអនុលោមភាព ការជំរុញការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម និងការងារត្រួតពិនិត្យគុណភាពសវនកម្ម។

នាយកដ្ឋានកិច្ចការច្បាប់បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារនីតិកម្ម វិវាទ ស្ថិតិ និងកិច្ចការអន្តរជាតិ។

នាយកដ្ឋានបច្ចេកទេសបំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងស្តង់ដាពាក់ព័ន្ធប្រហាក់ប្រហែល ព្រមទាំងការងារអភិវឌ្ឍវិជ្ជាជីវៈ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ។

**ប្រការ ៨.-**

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន១(មួយ)រូប អមដោយអនុប្រធាននាយកដ្ឋានអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

លេខាធិការដ្ឋាន ដឹកនាំដោយប្រធាន១(មួយ)រូប មានឋានៈនិងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន អមដោយអនុប្រធាន១(មួយ)រូប មានឋានៈនិងបុព្វសិទ្ធិស្មើប្រធានការិយាល័យ ជាជំនួយការ។

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យ ១(មួយ)រូប អមដោយអនុប្រធានការិយាល័យអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.** ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៣

## នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

**ប្រការ ៩.-**

នាយកដ្ឋានរដ្ឋបាលបុគ្គលិកនិងហិរញ្ញវត្ថុបំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងាររដ្ឋបាលបុគ្គលិក ហិរញ្ញវត្ថុ ផែនការថវិកា និងព័ត៌មានវិទ្យាដោយមានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយបុគ្គលិក គ្រប់គ្រង និងជ្រើសរើសបុគ្គលិក
- រៀបចំតារាងបៀវត្សនិងប្រាក់ឧបត្ថម្ភនានារបស់ថ្នាក់ដឹកនាំ និងមន្ត្រី **គ.ជ.គ.**
- គ្រប់គ្រងកិច្ចការរដ្ឋបាល និងចាត់ចែងការងារពិធីការរបស់ **គ.ជ.គ.**
- រៀបចំផែនការការងាររបស់ប្រធាន **គ.ជ.គ.** និងអគ្គលេខាធិការ **គ.ជ.គ.**
- ផ្គត់ផ្គង់និងគ្រប់គ្រងរាល់សម្ភារៈបរិក្ខារ
- ទទួលបន្ទុកការងារទំនាក់ទំនងសាធារណៈនៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- អនុវត្តនិងគ្រប់គ្រងការងារគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- រៀបចំនិងគ្រប់គ្រងផែនការថវិការបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- រៀបចំនិងគ្រប់គ្រងផ្នែកបច្ចេកទេសព័ត៌មានវិទ្យា
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់អគ្គលេខាធិការ **គ.ជ.គ.**។

**ប្រការ ១០.-**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុមានការិយាល័យចំនួន៤ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងបុគ្គលិក

២. ការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ

៣. ការិយាល័យផែនការថវិកា

៤. ការិយាល័យព័ត៌មានវិទ្យា។

**ប្រការ ១១.-**

ការិយាល័យរដ្ឋបាលនិងបុគ្គលិក មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- ទទួលការងារទំនាក់ទំនងសាធារណៈក្រៅពីទំនាក់ទំនងអន្តរជាតិ
- សម្របសម្រួល និងអនុវត្តគ្រប់ផ្នែកកិច្ចការរដ្ឋបាលទូទៅរបស់ **គ.ជ.គ.**
- រៀបចំចងក្រងទុកឯកសាររដ្ឋបាល និងឯកសារថតចម្លងផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- គ្រប់គ្រងចរន្តលិខិតចេញ និងចូលរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- ថតចម្លងច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ដើម្បីផ្សព្វផ្សាយជូនថ្នាក់ដឹកនាំ ឬអង្គភាព ពាក់ព័ន្ធតាមការណែនាំរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន
- រៀបចំចាត់ចែងការបោះពុម្ពឯកសារ និងបទប្បញ្ញត្តិផ្សេងៗរបស់ **គ.ជ.គ.**
- គ្រប់គ្រង និងផ្គត់ផ្គង់សម្ភារៈការិយាល័យ ទព្វសម្ភារៈ គ្រឿងបន្លាស់ផ្សេងៗដែលចាំបាច់សម្រាប់ដំណើរការរបស់ **គ.ជ.គ.**

- ធានាប្រសិទ្ធភាព សុវត្ថិភាពឯកសារ សុវត្ថិភាពរដ្ឋបាល សន្តិសុខ អនាម័យ និងគ្រប់គ្រងទីកន្លែងធ្វើការរបស់ **គ.ជ.គ.** ឱ្យបានល្អ
- ទទួលបន្ទុកគ្រប់គ្រង និងចាត់ចែងបន្ទប់ប្រជុំ
- រៀបចំចាត់ចែងទទួលបដិសណ្ឋារកិច្ចភ្ញៀវជាតិ និងអន្តរជាតិរបស់ **គ.ជ.គ.**
- តុបតែងលំអទីកន្លែងធ្វើការ **គ.ជ.គ.** រាល់ពិធីបុណ្យជាតិ និងអន្តរជាតិនានាទៅតាមការណែនាំរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ
- រៀបចំលិខិតថ្វាយព្រះពរ និងជូនពរព្រះមហាក្សត្រ និងថ្នាក់ដឹកនាំជាតិ
- ធ្វើបញ្ជីសារពើភណ្ឌ ចលនទ្រព្យ អចលនទ្រព្យ និងទ្រព្យសម្បត្តិផ្សេងៗដែលប្រើប្រាស់ដោយ **គ.ជ.គ.**
- រៀបចំផែនការបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- រៀបចំការងារជ្រើសរើសបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- រៀបចំនិងសម្របសម្រួលប័ណ្ណសំគាល់ខ្លួនរបស់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- ចាត់ចែងរៀបចំការវាយតម្លៃការជ្រើសរើស និងតម្រង់ទិសវិជ្ជាជីវៈជំនាញមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- ពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- ពិនិត្យការស្នើសុំអនុញ្ញាតច្បាប់ឈប់សម្រាក ព្យាបាលជំងឺ មានផ្ទៃពោះ ឬសម្រាកលំហែមាតុភាពនិងបិតុភាពរបស់មន្ត្រីអគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- បូកសរុបវត្តមានមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** ដោយរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំពិនិត្យ
- គ្រប់គ្រង និងរក្សាសំណុំឯកសារបុគ្គលិក ព្រមទាំងរៀបចំធ្វើសំណើតែងតាំងផ្ទេរភារកិច្ច ឬទទួលស្គាល់ការចូលនិវត្តន៍ ការសុំឈប់ ការលុបឈ្មោះរបស់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លិខិតបង្គាប់ការ ឬសេចក្តីសម្រេចនានារបស់ **គ.ជ.គ.** អំពីការងារបុគ្គលិក
- រៀបចំនិងផ្តល់យោបល់លើការវាយតម្លៃសម្រាប់ការដំឡើងមុខងារនិងថ្នាក់ដល់មន្ត្រី **គ.ជ.គ.**
- រៀបចំសម្របសម្រួលការងារលើកសរសើរ ផ្តល់កិត្តិយស ដាក់ពិន័យ ស្តីបន្ទោស ឬព្រមានដល់មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- រៀបចំបញ្ជីរាយនាមមន្ត្រីសម្រាប់បើកប្រាក់បៀវត្ស
- ស្នើសុំឬលើកសំណើចាត់មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.** ចូលរួមក្នុងរាល់សកម្មភាពបុណ្យជាតិ អន្តរជាតិ ឬសកម្មភាពសង្គមនានា តាមតម្រូវការចាំបាច់
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ១២.-**

ការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ មានមុខងារនិងភារកិច្ច ដូចខាងក្រោម÷

- ចូលរួមការងារប្រមូលចំណូលកម្រៃសេវារដ្ឋបាលផ្សេងៗ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- លើកសំណើ និងអនុវត្តលទ្ធកម្មសាធារណៈរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- ពិនិត្យ និងតាមដានការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈសម្រាប់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- គ្រប់គ្រងការអនុវត្តថវិកា គណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**

- បើកប្រាក់បៀវត្សជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** តាមបញ្ជីផ្តល់ឱ្យដោយការិយាល័យបុគ្គលិក
- ធ្វើការបើក និងបិទបញ្ជិកាគណនេយ្យសម្រាប់ការិយបរិច្ឆេទនៃឆ្នាំនីមួយៗ
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ១៣.-**

ការិយាល័យផែនការថវិកា មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា កញ្ចប់ថវិកាប្រចាំឆ្នាំ និងរបាយការណ៍ថវិកាសម្រេចទូទាត់របស់ **គ.ជ.គ**
- រៀបចំ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ **គ.ជ.គ.**
- រៀបចំគម្រោងផែនការ និងបូកសរុបថវិកាចំណូល ចំណាយប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ **គ.ជ.គ.**
- រៀបចំគម្រោងថវិកា និងតាមដានការអនុវត្តថវិការបស់ **គ.ជ.គ.**
- រៀបចំធ្វើនិយ័តកម្មថវិការបស់ **គ.ជ.គ.** ដើម្បីធានាការអនុវត្តចំណាយក្នុងឆ្នាំ
- រៀបចំ និងត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំរបស់ **គ.ជ.គ.**
- រៀបចំនិងបូកសរុបរបាយការណ៍សមិទ្ធកម្មលទ្ធផលរបស់ **គ.ជ.គ.**
- រៀបចំ និងវិភាជន៍ចំណាយថវិកាប្រចាំឆ្នាំរបស់ **គ.ជ.គ.**
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ១៤.-**

ការិយាល័យព័ត៌មានវិទ្យា មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំ បង្កើត និងគ្រប់គ្រងគេហទំព័រ សារអេឡិចត្រូនិចប្រព័ន្ធផ្សព្វផ្សាយ កម្មវិធីអេឡិចត្រូនិច និងមូលដ្ឋានទិន្នន័យរបស់ **គ.ជ.គ.**
- បញ្ចូលព័ត៌មាន និងធ្វើបច្ចុប្បន្នកម្មទិន្នន័យស្តីពីវិជ្ជាជីវៈដែលទទួលបានពីនាយកដ្ឋានពាក់ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- រៀបចំនិងបង្កើតប្រព័ន្ធគណនេយ្យកុំព្យូទ័រសម្រាប់គាំទ្រដល់ការងារអនុលោមភាពទៅនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- តំឡើង និងគ្រប់គ្រង ម៉ាស៊ីនមេ បណ្តាញកុំព្យូទ័រ អ៊ីនធើណេត អ៊ីនត្រាណែត និងផ្នែករឹងនៃឧបករណ៍ព័ត៌មានវិទ្យា ឱ្យមានប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- គ្រប់គ្រង និងថែទាំប្រព័ន្ធកុំព្យូទ័រ សម្ភារៈព័ត៌មានវិទ្យា ផ្តល់សេវាព័ត៌មានវិទ្យាសម្រាប់ដំណើរការ **គ.ជ.គ.**
- តាមដានជាប្រចាំលើដំណើរការបណ្តាញកុំព្យូទ័រ អ៊ីនធើណេត និងអ៊ីនត្រាណែត ដោយសិក្សាពីមូលហេតុដែលបណ្តាលឱ្យរអាក់រអួល និងស្វែងរកដំណោះស្រាយឱ្យបានឆាប់រហ័ស
- ធានាសុវត្ថិភាពកុំព្យូទ័រ បណ្តាញកុំព្យូទ័រ មូលដ្ឋានទិន្នន័យ និងម៉ាស៊ីនមេ

- លើកសំណើអំពីតម្រូវការចាំបាច់នៃកម្មវិធីកុំព្យូទ័រ គ្រឿងបន្លាស់ សម្ភារៈកុំព្យូទ័រ និងការភ្ជាប់បន្ថែមនូវប្រព័ន្ធអ៊ីនធើណេត
- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍផ្នែកព័ត៌មានវិទ្យា សម្រាប់ **គ.ជ.គ.**
- រៀបចំសេចក្តីណែនាំក្នុងការប្រើប្រាស់កុំព្យូទ័រ កម្មវិធីកុំព្យូទ័រ បណ្តាញកុំព្យូទ័រ អ៊ីនធើណេត អ៊ីនត្រាណែត និងបច្ចេកទេសពាក់ព័ន្ធ តាមតម្រូវការការងាររបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- សហការជាមួយស្ថាប័នពាក់ព័ន្ធនានា និងដៃគូផ្សេងៗក្នុងការអភិវឌ្ឍផ្នែកព័ត៌មានវិទ្យា
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

## ជំពូកទី៤
## នាយកដ្ឋានអនុលោមភាព និងត្រួតពិនិត្យ

**ប្រការ ១៥.-**

នាយកដ្ឋានអនុលោមភាពនិងត្រួតពិនិត្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារអនុលោមភាព ការជំរុញការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មនិងការងារត្រួតពិនិត្យគុណភាពសវនកម្ម ដោយមានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងកិច្ចការត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- គ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម
- គ្រប់គ្រងការងារត្រួតពិនិត្យ និងវាយតម្លៃគុណភាពគណនេយ្យនិងសវនកម្ម
- អនុវត្តការត្រួតពិនិត្យលើអនុលោមភាពទៅនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- អនុវត្តការផ្តល់ ការបន្តសុពលភាព ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- ធ្វើអធិការកិច្ចគុណភាពគណនេយ្យ និងសវនកម្ម
- ត្រួតពិនិត្យ និងតម្កល់របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ពិនិត្យនិងស្នើយោបល់ដើម្បីចាត់វិធានការដាក់ពិន័យនិងវិធានការចាំបាច់នានា ចំពោះបុគ្គលដែលបំពានច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងអនុវត្តការផាកពិន័យអន្តរការណ៍
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើស្តង់ដាសវនកម្មនិងការអះអាង ស្តង់ដាគុណភាពសវនកម្ម និងក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងស្តង់ដាពាក់ព័ន្ធផ្សេងទៀត
- ចូលរួមរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិនានា និងលើកសំណើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងអនុលោមភាពគណនេយ្យនិងសវនកម្ម
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីទប់ស្កាត់បទល្មើសនៃការប្រកបអាជីវកម្មគណនេយ្យនិងសវនកម្ម ព្រមទាំងចូលរួមចំណែកកំណត់វិធាន នីតិវិធី និងចាត់វិធានការទប់ស្កាត់និងបង្ក្រាបការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- អនុវត្តការងារផ្សេងទៀតតាមការកំណត់របស់អគ្គលេខាធិការ **គ.ជ.គ.**។

**ប្រការ ១៦.-**

នាយកដ្ឋានអនុលោមភាព និងត្រួតពិនិត្យ មានការិយាល័យក្រោមឱវាទចំនួន៣ ដូចខាងក្រោម÷

១. ការិយាល័យអនុលោមភាព

២. ការិយាល័យអាជ្ញាបណ្ណ

៣. ការិយាល័យត្រួតពិនិត្យ

**ប្រការ ១៧.-**

ការិយាល័យអនុលោមភាព មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់ការគ្រប់គ្រងនិងត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន **ក.ម.គ.**
- អនុវត្តការងារត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តច្បាប់ស្ដីពីគណនេយ្យនិងសវនកម្មដោយសហគ្រាស និងអង្គភាពមិនស្វែងរកចំណេញ
- ពិនិត្យ និងលើកសំណើ ទណ្ឌកម្មពិន័យ និងវិធានការរដ្ឋបាលចំពោះបទល្មើសនឹងច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម
- រៀបចំផែនការ តាមដាន អនុវត្ត និងវាយតម្លៃការងារអនុលោមភាពនៃការអនុវត្តច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម
- រៀបចំប្រព័ន្ធគ្រប់គ្រង និងគ្រប់គ្រងទិន្នន័យសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- អនុវត្តការពិន័យអន្តរការណ៍លើបុគ្គលប្រព្រឹត្តល្មើសទៅនឹងច្បាប់គណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ
- ពិនិត្យ និងតម្កល់របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ១៨.-**

ការិយាល័យអាជ្ញាបណ្ណ មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំនីតិវិធីនិងបែបបទសម្រាប់ការផ្ដល់អាជ្ញាបណ្ណ ការបន្តសុពលភាពអាជ្ញាបណ្ណ ការព្យួរ និងការដកហូតអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម
- អនុវត្តការងារពាក់ព័ន្ធនឹងការផ្ដល់ បន្តសុពលភាព ការព្យួរនិងដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- រៀបចំផែនការ តាមដាន អនុវត្ត និងវាយតម្លៃការងារផ្ដល់អាជ្ញាបណ្ណគណនេយ្យនិងសវនកម្ម
- រៀបចំប្រព័ន្ធគ្រប់គ្រង និងគ្រប់គ្រងទិន្នន័យសហគ្រាសក្រុមហ៊ុនគណនេយ្យនិងសវនកម្ម
- អនុវត្តការងារផ្សេងទៀតតាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ១៩.-**

ការិយាល័យត្រួតពិនិត្យ មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំក្របខ័ណ្ឌនីតិវិធី បែបបទ និងសេចក្តីណែនាំ សម្រាប់ត្រួតពិនិត្យនិងវាយតម្លៃគុណភាពគណនេយ្យនិងសវនកម្ម
- អនុវត្តការងារធ្វើអធិការកិច្ចលើការអនុវត្តស្តង់ដាសវនកម្មនិងការអះអាង ស្តង់ដាគុណភាពសវនកម្ម និងក្រមសីលធម៌វិជ្ជាជីវៈ
- រៀបចំផែនការ តាមដាន អនុវត្ត និងវាយតម្លៃការងារត្រួតពិនិត្យគុណភាពគណនេយ្យនិងសវនកម្ម
- ផ្តល់យោបល់បច្ចេកទេសលើស្តង់ដាសវនកម្មនិងការអះអាង ស្តង់ដាគុណភាពសវនកម្ម និងក្រមសីលធម៌វិជ្ជាជីវៈ
- ពិនិត្យនិងលើកសំណើទណ្ឌកម្មពិន័យ និងវិធានការរដ្ឋបាលចំពោះក្រុមហ៊ុនគណនេយ្យនិងសវនកម្ម
- អនុវត្តការងារផ្សេងទៀតតាមការកំណត់របស់ប្រធាននាយកដ្ឋាន។

## ជំពូកទី៥

## នាយកដ្ឋានកិច្ចការច្បាប់

**ប្រការ ២០.-**

នាយកដ្ឋានកិច្ចការច្បាប់ បំពេញមុខងារជាលេខាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារនីតិកម្ម វិវាទ ស្ថិតិ និងកិច្ចការអន្តរជាតិ ដោយមានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងកិច្ចការច្បាប់ និងសម្របសម្រួលការងារនីតិកម្មក្នុង **គ.ជ.គ.**
- សិក្សាស្រាវជ្រាវ និងប្រមូលចងក្រងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាលគំរូ តាមវិស័យជំនាញក្នុងសមត្ថកិច្ចរបស់ **គ.ជ.គ.**
- ចូលរួមត្រួតពិនិត្យ និងតាមដានការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យគណនេយ្យ និងសវនកម្មជាមួយនាយកដ្ឋានពាក់ព័ន្ធនានា
- ពិនិត្យសង្គតិភាពនីត្យានុកូលភាពនិងសុខដុមភាពនៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលជាសមត្ថកិច្ចរបស់ **គ.ជ.គ.**
- ផ្តល់មតិប្រឹក្សាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរួមទាំងកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងៗ
- ការពារផលប្រយោជន៍ខាងផ្លូវច្បាប់របស់ **គ.ជ.គ.** នៅចំពោះមុខស្ថាប័នដទៃទៀត រួមទាំងតុលាការ
- រៀបចំបែបបទ និងធ្វើសំណើចាត់វិធានការនានា ចំពោះអ្នកបំពានច្បាប់គណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ
- សម្របសម្រួល និងដោះស្រាយការតវ៉ាដែលកើតមានក្នុងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- គ្រប់គ្រងការងារស្ថិតិនៃវិវាទនិងអំពើល្មើស
- គ្រប់គ្រងកិច្ចការអន្តរជាតិ និងចូលរួមក្នុងកិច្ចអភិវឌ្ឍនីតិកម្មក្នុងវិស័យគណនេយ្យនិងសវនកម្មក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់អគ្គលេខាធិការ **គ.ជ.គ.**។

**ប្រការ ២១.-**

នាយកដ្ឋានកិច្ចការច្បាប់ មានការិយាល័យក្រោមឱវាទចំនួន៣ ដូចខាងក្រោម÷

១. ការិយាល័យនីតិកម្ម

២. ការិយាល័យវិវាទ និងស្ថិតិ

៣. ការិយាល័យកិច្ចការអន្តរជាតិ

**ប្រការ ២២.-**

ការិយាល័យនីតិកម្ម មានមុខងារ និងភារកិច្ចដូចខាងក្រោយ÷

- សិក្សាស្រាវជ្រាវការវិវឌ្ឍថ្មីៗនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម
- រៀបចំប្រព័ន្ធទិន្នន័យច្បាប់ តាមវិស័យជំនាញ
- លើកសំណើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិចាំបាច់នានាដើម្បីជំរុញដល់ការអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម
- ពិនិត្យសង្គតភាព នីត្យានុកូលភាព សុខដុមភាពនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងផ្តល់មតិប្រឹក្សាច្បាប់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម
- ផ្តល់មតិប្រឹក្សាច្បាប់ក្រោមទម្រង់ជាការបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ចូលរួមត្រួតពិនិត្យនិងតាមដានការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្មជាមួយការិយាល័យពាក់ព័ន្ធនានា
- រៀបចំចងក្រងមគ្គុទេសក៍នីតិកម្មសម្រាប់វិស័យគណនេយ្យនិងសវនកម្ម
- ផ្តល់ការបណ្តុះបណ្តាលបន្ថែមអំពីកិច្ចការច្បាប់ដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន **ក.ជ.គ.** តាមការចាំបាច់
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ២៣.-**

ការិយាល័យវិវាទ និងស្ថិតិ មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំយន្តការ បែបបទ និងនីតិវិធីដោះស្រាយការតវ៉ា និងវិវាទ
- សម្របសម្រួលការតវ៉ា និងវិវាទ ក្នុងវិស័យគណនេយ្យ និងសវនកម្ម
- សិក្សា និងកំណត់ចំណុចខ្វះខាត និងចំណុចខ្សោយនៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ
- ធានាទំនាក់ទំនងជាមួយនឹងតុលាការ
- ចងក្រងស្ថិតិការតវ៉ា និងវិវាទក្នុងវិស័យគណនេយ្យ និងសវនកម្ម
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ២៤.-**

ការិយាល័យកិច្ចការអន្តរជាតិមានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំផែនការបង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ស្ថាប័នជាតិនិងអន្តរជាតិនានា

- កសាងរក្សាពង្រឹងចំណងមិត្តភាពនិងធ្វើទំនាក់ទំនង ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា
- ទំនាក់ទំនងរកជំនួយកិច្ចសហប្រតិបត្តិការរួមទាំងហិរញ្ញប្បទានឥតសំណងពីស្ថាប័នសមភាគីនានាក្នុងការអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្មក្នុងប្រទេសកម្ពុជា
- សម្របសម្រួលកម្មវិធីបេសកកម្មក្រៅប្រទេសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃ **គ.ជ.គ.**
- ផ្តល់យោបល់ និងលើកសំណើ ដើម្បីបំពេញលក្ខខណ្ឌសមាជិករបស់ស្ថាប័នអន្តរជាតិពាក់ព័ន្ធវិស័យគណនេយ្យនិងសវនកម្ម ដែលផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ជំពូកទី៦**

**នាយកដ្ឋានបច្ចេកទេស**

**ប្រការ ២៥.-**

នាយកដ្ឋានបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងអភិវឌ្ឍវិជ្ជាជីវៈនិងបណ្តុះបណ្តាល ដោយមានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ **គ.ជ.គ.**
- សិក្សា និងស្រាវជ្រាវ អំពីការវិវឌ្ឍនៃស្តង់ដាគណនេយ្យ និងសវនកម្ម
- រៀបចំតាក់តែងសេចក្តីព្រាងស្តង់ដាគណនេយ្យនិងសវនកម្ម តាមការកំណត់របស់ **គ.ជ.គ.**
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើបច្ចេកទេសស្តង់ដាគណនេយ្យ និងសវនកម្មជាមួយភាគីពាក់ព័ន្ធ
- ចូលរួមជាមួយស្ថាប័នតំបន់ និងអន្តរជាតិក្នុងការងាររៀបចំ និងអភិវឌ្ឍស្តង់ដាគណនេយ្យ និងសវនកម្ម
- ពិនិត្យ និងផ្តល់យោបល់លើការងារស្តង់ដាគណនេយ្យក្នុងក្របខ័ណ្ឌអន្តរជាតិ
- រៀបចំការផ្សព្វផ្សាយពីខ្លឹមសារនៃស្តង់ដាគណនេយ្យនិងសវនកម្ម ដោយសហការជាមួយនាយកដ្ឋានជំនាញផ្សេងទៀតរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- បកស្រាយអំពីបច្ចេកទេសស្តង់ដាគណនេយ្យ និងសវនកម្មដល់ភាគីពាក់ព័ន្ធ
- ជំរុញការអនុវត្តស្តង់ដាគណនេយ្យ និងសវនកម្ម នៅព្រះរាជាណាចក្រកម្ពុជា
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ និងសវនកម្ម ឬការធ្វើវិសោធនកម្មនានា ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធផ្សេងទៀត របស់ **គ.ជ.គ.**
- ធ្វើជាសេនាធិការលើបច្ចេកទេសស្តង់ដាពាក់ព័ន្ធវិស័យគណនេយ្យនិងសវនកម្មជូនអគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- រៀបចំ សម្របសម្រួល និងគ្រប់គ្រងកម្មវិធីអប់រំ បណ្តុះបណ្តាលនិងផ្សព្វផ្សាយ
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់អគ្គលេខាធិការ **គ.ជ.គ.**។

**ប្រការ ២៦.-**

នាយកដ្ឋានបច្ចេកទេស មានការិយាល័យចំនួន៣ ដូចខាងក្រោម÷

១. ការិយាល័យស្តង់ដាគណនេយ្យ

២. ការិយាល័យស្តង់ដាសវនកម្ម

៣. ការិយាល័យអភិវឌ្ឍវិជ្ជាជីវៈ និងបណ្តុះបណ្តាល។

**ប្រការ ២៧.-**

ការិយាល័យស្តង់ដាគណនេយ្យមានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- សិក្សានិងស្រាវជ្រាវអំពីការវិវឌ្ឍនៃស្តង់ដាគណនេយ្យសម្រាប់វិស័យឯកជនវិស័យសាធារណៈ សហគ្រាស និងសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ
- រៀបចំតាក់តែងសេចក្តីព្រាងស្តង់ដាគណនេយ្យសម្រាប់វិស័យឯកជនវិស័យសាធារណៈ សហគ្រាស និងសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើបច្ចេកទេសស្តង់ដាគណនេយ្យ ជាមួយភាគីពាក់ព័ន្ធ និងបោះផ្សាយជាសាធារណៈនូវសេចក្តីព្រាងស្តង់ដាគណនេយ្យដើម្បីទទួលបានមតិយោបល់ពីភាគីពាក់ព័ន្ធបន្ថែមទៀត
- ពិនិត្យ និងផ្តល់យោបល់លើការងារស្តង់ដាគណនេយ្យក្នុងក្របខ័ណ្ឌអន្តរជាតិ
- រៀបចំការផ្សព្វផ្សាយពីខ្លឹមសារនៃស្តង់ដាគណនេយ្យ ដោយសហការជាមួយនាយកដ្ឋានជំនាញផ្សេងទៀតរបស់អគ្គលេខាធិការដ្ឋាន **ក.ជ.គ.**
- ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសស្តង់ដាគណនេយ្យដល់ភាគីពាក់ព័ន្ធ
- ធ្វើការណែនាំពីបែបបទ និងនីតិវិធីនៃការអនុវត្តស្តង់ដាគណនេយ្យដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញ សហគ្រាស និងស្ថាប័នសាធារណៈ
- បកស្រាយអំពីបច្ចេកទេសស្តង់ដាគណនេយ្យ
- សម្របសម្រួលការងារបកប្រែស្តង់ដាគណនេយ្យមកខេមរភាសា និងបច្ចេកស័ព្ទពាក់ព័ន្ធ
- ចូលរួមជំរុញ ការអនុវត្តស្តង់ដារគណនេយ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធផ្សេងទៀតរបស់ **ក.ជ.គ.**
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ២៨.-**

ការិយាល័យស្តង់ដាសវនកម្មមានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- សិក្សានិងស្រាវជ្រាវអំពីការវិវឌ្ឍនៃស្តង់ដាសវនកម្មជាលក្ខណៈអន្តរជាតិ
- រៀបចំតាក់តែងសេចក្តីព្រាងស្តង់ដាសវនកម្ម
- បោះផ្សាយជាសាធារណៈនូវសេចក្តីព្រាងនៃស្តង់ដាសវនកម្ម ដើម្បីទទួលបានមតិយោបល់ពីភាគីពាក់ព័ន្ធសម្រាប់ឱ្យសាធារណជនធ្វើការបញ្ចេញមតិយោបល់
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើបច្ចេកទេសស្តង់ដាសវនកម្ម ជាមួយភាគីពាក់ព័ន្ធ

- រៀបចំការផ្សព្វផ្សាយពីខ្លឹមសារនៃស្តង់ដាសវនកម្មដោយសហការជាមួយនាយកដ្ឋានជំនាញផ្សេងទៀតរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.គ.**
- ធ្វើការណែនាំពីបែបបទ និងនីតិវិធីនៃការអនុវត្តស្តង់ដាសវនកម្មដល់សវនករ
- ចូលរួមជំរុញ ការអនុវត្តស្តង់ដាសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ដាក់ឱ្យអនុវត្តស្តង់ដាសវនកម្មដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធផ្សេងទៀតរបស់ **គ.ជ.គ.**
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ ២៩.-**

ការិយាល័យអភិវឌ្ឍវិជ្ជាជីវៈនិងបណ្តុះបណ្តាលមានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែង សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- ត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តផែនការយុទ្ធសាស្ត្រដែលបានដាក់ចេញ
- ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រស្របទៅតាមស្ថានភាពជាក់ស្តែងនៃកម្ពុជា
- សម្របសម្រួលការរៀបចំផែនការសកម្មភាព របស់ **គ.ជ.គ.**
- បង្កើត សម្របសម្រួល និងគ្រប់គ្រងកម្មវិធីអប់រំបណ្តុះបណ្តាល និងផ្សព្វផ្សាយ
- រៀបចំកម្មវិធីអប់រំបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាបច្ចេកទេសផ្សេងៗ ដល់ភាគីពាក់ព័ន្ធ
- រៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការបណ្តុះបណ្តាល
- រៀបចំបែបបទ នីតិវិធី និងលក្ខខណ្ឌសំរាប់ការបណ្តុះបណ្តាល
- រៀបចំគម្រោងផែនការសម្រាប់ការបណ្តុះបណ្តាលផ្សេងៗ ពាក់ពន្ធនឹងវិស័យគណនេយ្យ និងសវនកម្មកម្ពុជាសម្រាប់ឆ្នាំបន្ទាប់
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ជំពូកទី៧**

**លេខាធិការដ្ឋាន**

**ប្រការ ៣០.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.គ.** មានលេខាធិការដ្ឋានមួយបំពេញមុខងារជាសេនាធិការរដ្ឋបាល និងបច្ចេកទេសរបស់អគ្គលេខាធិការ។

**ប្រការ ៣១.-**

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការផ្ទាល់ឱ្យអគ្គលេធិការ លើការងារដូចតទៅ៖

- ទទួលបន្ទុកជាជំនួយការអគ្គលេខាធិការ លើប្រតិបត្តិការការងារប្រចាំថ្ងៃ
- រៀបចំផែនការការងារសម្រាប់អគ្គលេខាធិការ
- ត្រួតពិនិត្យបណ្តាឯកសារ សេចក្តីព្រាងសំណើសុំ និងលិខិតផ្សេងៗ មុននឹងបញ្ជូនទៅសុំការសម្រេចពីអគ្គ-លេខាធិការ

- សម្របសម្រួលការងារផ្ទៃក្នុងអគ្គលេខាធិការដ្ឋាននិងសម្របសម្រួលការងារជាមួយនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធដទៃទៀត ក្នុងនាមនិងតាមបញ្ជារបស់អគ្គលេខាធិការ
- គ្រប់គ្រង និងចរាចរលិខិតចេញ-ចូល និងលិខិតស្នាមផ្សេងៗរបស់អគ្គលេខាធិការ
- រៀបចំសេចក្ដីព្រាងសំណើ និងលិខិតផ្សេងៗ និងធ្វើកំណត់ហេតុប្រជុំដើម្បីដាក់ជូនអគ្គលេខាធិការ
- ប្រមូលសរុបរបាយការណ៍សកម្មភាពការងារ របស់អគ្គលិខាធិការដ្ឋានប្រចាំត្រីមាស ឆមាស និងឆ្នាំ ដើម្បីដាក់ជូនអគ្គលេខាធិការ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គលេខាអធិការ **គ.ជ.គ.**។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ ៣២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣៣.-**

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.គ នាយកវិទ្យាស្ថាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៣៣

"**ដើម្បីអនុវត្ត**"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ[illegible] សហវ.ប្រក.
ចុះថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១៨

## អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគណនេយ្យ



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..[illegible].....សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់ និងការគោរពកាតព្វកិច្ចពន្ធមួយចំនួនរបស់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវា ក្នុងនាមសហគ្រាសដើម

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងតាមតម្រូវការចាំបាច់នៃការគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់វិធាន និងនីតិវិធីនៃការទទួលស្គាល់ និងការបំពេញកាតព្វកិច្ចពន្ធមួយចំនួនរបស់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ស្របតាមមាត្រា៥២ នៃអនុក្រឹត្យស្ដីពីអាករលើតម្លៃបន្ថែម។

### ប្រការ ២.- គោលដៅ

ប្រកាសនេះ មានគោលដៅកំណត់លក្ខខណ្ឌនៃការផ្គត់ផ្គត់ផ្គង់ទំនិញឬសេវារបស់ភ្នាក់ងារក្នុងនាមសហគ្រាសដើម។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធមធ្យមឬអ្នកជាប់ពន្ធធំ ដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវា ក្នុងនាមសហគ្រាសដើមជាអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៤.- លក្ខខណ្ឌដើម្បីទទួលបានលក្ខណសម្បត្តិជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម

អនុលោមតាមមាត្រា៥២ នៃអនុក្រឹត្យស្ដីពីអាករលើតម្លៃបន្ថែមការផ្គត់ផ្គង់ទំនិញឬសេវាធ្វើឡើងដោយបុគ្គលជាភ្នាក់ងារ ដើម្បីជាគុណប្រយោជន៍របស់បុគ្គលម្នាក់ទៀតដែលជាសហគ្រាសដើម ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់របស់សហគ្រាសដើមនោះ។ ដើម្បីទទួលបានលក្ខណសម្បត្តិជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ភ្នាក់ងារត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

ក. ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ត្រូវតែជាអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ។

ខ. ត្រូវមានកិច្ចសន្យារវាងសហគ្រាសដើមនិងភ្នាក់ងារ និងឯកសារគាំទ្រផ្សេងៗដែលបញ្ជាក់អំពីទំនាក់ទំនងគ្នារវាងសហគ្រាសដើមនិងភ្នាក់ងារ។

គ. សហគ្រាសដើម ត្រូវកំណត់តម្លៃទំនិញឬសេវា ព្រមទាំងកម្រៃជើងសា ឱ្យភ្នាក់ងារ។

ឃ. សន្និធិទំនិញ នៅតែជាកម្មសិទ្ធិរបស់សហគ្រាសដើម នៅពេលដែលទំនិញមិនទាន់ត្រូវបានផ្គត់ផ្គង់។

ង. នៅពេលផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន ភ្នាក់ងារអាចប្រើប្រាស់វិក្កយបត្ររបស់ខ្លួន ដោយរំលេចឈ្មោះរបស់សហគ្រាសដើម ឬប្រើប្រាស់វិក្កយបត្ររបស់សហគ្រាសដើម។ សហគ្រាសដើម និងភ្នាក់ងារត្រូវជ្រើសរើសការប្រើប្រាស់វិក្កយបត្រណាមួយក្នុងចំណោមវិក្កយបត្រទាំងពីរប្រភេទ ហើយប្រើប្រាស់ពេញមួយឆ្នាំជាប់ពន្ធ។ វិក្កយបត្រត្រូវមានលំដាប់លេខរៀងដោយឡែកសម្រាប់សហគ្រាសដើមនីមួយៗ។

ច. ភ្នាក់ងារត្រូវចេញវិក្កយបត្រអាករ លើកម្រៃជើងសាពីការផ្គត់ផ្គង់ទំនិញឬសេវាឱ្យសហគ្រាសដើម។ សហគ្រាសដើម ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលនូវអាករលើតម្លៃបន្ថែមដែលបានបង់ទៅឱ្យភ្នាក់ងារ។

ឆ. ភ្នាក់ងារត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ខែនូវតារាងលម្អិតអំពីការផ្គត់ផ្គង់ទំនិញ ឬសេវា (ដូចមានគំរូភ្ជាប់ក្នុងឧបសម្ព័ន្ធ) ហើយត្រូវរាយការណ៍អំពីចលនាសន្និធិជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ត្រីមាស យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ក្រោយដំណាច់ត្រីមាសនីមួយៗ។

**ប្រការ ៥.- ការស្នើសុំទទួលស្គាល់ជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវា ក្នុងនាមសហគ្រាសដើម**

១. សហគ្រាសដូចមានចែងក្នុងប្រការ៤ ខាងលើ ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម មកអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

ក. កិច្ចសន្យាភ្នាក់ងារទទួលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម។

ខ. ឯកសារចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធជាអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ។

គ. គំរូវិក្កយបត្រដូចមានចែងក្នុងកថាខណ្ឌ ង នៃប្រការ ៤ នៃប្រកាសនេះ។

២. អគ្គនាយកដ្ឋានពន្ធដារ ត្រូវចេញលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ដែលមានសុពលភាព ០២ (ពីរ) ឆ្នាំ។

៣. ភ្នាក់ងារត្រូវជូនដំណឹងយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ មកអគ្គនាយកដ្ឋានពន្ធដារ ក្រោយពេលមានការផ្លាស់ប្តូរព័ត៌មាន ឬបញ្ឈប់កិច្ចសន្យារវាងភ្នាក់ងារនិងសហគ្រាសដើម។

៤. សហគ្រាសដែលបានទទួលលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម មិនអាចផ្ទេរសិទ្ធិផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ឱ្យបុគ្គលដទៃទៀតឡើយ។

៥. ក្នុងករណីមិនបានបំពេញលក្ខខណ្ឌតម្រូវណាមួយដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ លិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើមនឹងត្រូវអស់សុពលភាពភ្លាម ហើយសហគ្រាសត្រូវអនុវត្តតាមវិធាននៃការផ្គត់ផ្គង់ទំនិញឬសេវាជាធម្មតា។

**ប្រការ ៦.- ការស្នើសុំបន្តសុពលភាពជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម**

១. សហគ្រាសដែលស្នើសុំបន្តសុពលភាពជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារយ៉ាងយឺតបំផុត ៣០ថ្ងៃ មុនពេលផុតសុពលភាព ទៅតាមទម្រង់ដែលបានកំណត់ និងត្រូវភ្ជាប់មកជាមួយនូវឯកសារនានា ដូចខាងក្រោម÷

ក. ច្បាប់ចម្លងនៃលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម។

ខ. វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម) និងប័ណ្ណពន្ធប៉ាតង់។

គ. កិច្ចសន្យាភ្នាក់ងារទទួលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម។

២. ក្នុងករណីមិនបានស្នើសុំបន្តសុពលភាពដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ សហគ្រាសលែងត្រូវបានទទួលស្គាល់ជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ហើយការផ្គត់ផ្គង់ទំនិញឬសេវាត្រូវចាត់ទុកជាប្រតិបត្តិការធម្មតា មិនស្ថិតក្រោមលក្ខណសម្បត្តិជាភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើមឡើយ។

**ប្រការ ៧.- កម្រៃសេវាលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម**

ភ្នាក់ងារត្រូវបង់កម្រៃសេវាចំនួន ៤០០ ០០០៛ (បួនរយពាន់រៀល) សម្រាប់ការស្នើសុំលិខិតបញ្ជាក់ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម និង ២០០ ០០០៛ (ពីររយពាន់រៀល) សម្រាប់ការស្នើសុំបន្តសុពលភាព។

**ប្រការ ៨.- ការបំពេញកាតព្វកិច្ចពន្ធអាកររបស់ភ្នាក់ងារ**

១. ភ្នាក់ងារផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើមត្រូវបំពេញកាតព្វកិច្ចសារពើពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។ សម្រាប់គោលដៅនៃការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ភ្នាក់ងារត្រូវមានកាតព្វកិច្ចប្រមូលពន្ធអាករនានាជំនួសមុខឱ្យសហគ្រាសដើម ក៏ប៉ុន្តែពុំមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ជូនរដ្ឋបាលសារពើពន្ធទេ ដោយហេតុថាពន្ធអាករទាំងនេះ ជាកាតព្វកិច្ចរបស់សហគ្រាសដើម។ ពន្ធអាករដែលត្រូវប្រមូលជំនួសមុខឱ្យសហគ្រាសដើមមានដូចខាងក្រោម÷

ក. **អាករពិសេសលើទំនិញនិងសេវាមួយចំនួន÷** ក្នុងករណីដែលទំនិញឬសេវាណាមួយត្រូវជាប់អាករពិសេសលើទំនិញនិងសេវាមួយចំនួន ភ្នាក់ងារត្រូវគិតអាករនេះដោយផ្អែកលើមូលដ្ឋាន និងអត្រា ដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីអាករពិសេសលើទំនិញនិងសេវាមួយចំនួន។

ខ. **អាករសម្រាប់បំភ្លឺសាធារណៈ÷** ក្នុងករណីដែលទំនិញណាមួយត្រូវជាប់អាករសម្រាប់បំភ្លឺសាធារណៈ ភ្នាក់ងារត្រូវគិតអាករនេះដោយផ្អែកលើមូលដ្ឋាន និងអត្រាដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ។

គ. **អាករលើតម្លៃបន្ថែម÷** រាល់ការផ្គត់ផ្គង់ទំនិញឬសេវា ភ្នាក់ងារត្រូវគិតអាករលើតម្លៃបន្ថែមលើមូលដ្ឋានតម្លៃសរុបរួមបញ្ចូលអាករទាំងអស់លើកលែងតែអាករលើតម្លៃបន្ថែមខ្លួនឯង។

២. ចំពោះកម្រៃដែលបានពីការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើម ភ្នាក់ងារត្រូវចេញវិក្កយបត្រអាករទៅឱ្យសហគ្រាសដើម ដោយគិតអាករលើតម្លៃបន្ថែម និងធ្វើការប្រកាសបង់អាករនេះ និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលជូនរដ្ឋបាលសារពើពន្ធ តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ កម្រៃដែលទទួលបានពីការផ្គត់ផ្គង់ទំនិញឬសេវាក្នុងនាមសហគ្រាសដើមនេះ មិនមែនជាកម្មវត្ថុនៃអាករសម្រាប់បំភ្លឺសាធារណៈទេ។

**ប្រការ ៩.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ឬអគ្គនាយក នៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៨

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឈ្មោះបុគ្គលដើម៖............................ VATTIN: ............................ (តារាងឧបសម្ព័ន្ធ)

ឈ្មោះភ្នាក់ងារ៖................................ VATTIN: ............................

អាសយដ្ឋានភ្នាក់ងារ៖........................

## តារាងលម្អិតអំពីការលក់ប្រចាំខែ........ឆ្នាំ........

## Detail Sales Table

| វិក្កយបត្រ (Invoice) | | | | | | សរុបថ្លៃលក់រួមទាំងអាករ Total Value Including VAT |
|---|---|---|---|---|---|---|
| ថ្ងៃទី Date | លេខវិក្កយបត្រ Invoice No | អ្នកទិញ Customer | លេខអតប VAT No | បរិយាយ DESCRIPTION | បរិមាណ Quantity | |
| T1 | T2 | T3 | T4 | T5 | T6 | T7 |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | សរុបជារៀល | | |

សម្គាល់÷

- បើអ្នកទិញ ជាបុគ្គលជាប់អាករ ត្រូវបំពេញប្រអប់ (T4)

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី